


## វេទិកាសិល្បៈស្ត្រី ....

ក្តៅរួមទាំងសេវាមូលដ្ឋាននានាដែលស្ត្រីត្រូវការជាចាំបាច់នោះទេ។

លោកស្រីបន្តថា៖«ស្ត្រីជាច្រើនរួមទាំងកុមារីទទួលរងនូវការរំលោភបំពានទាំងផ្លូវកាយ និងផ្លូវចិត្ត ផ្លូវភេទអារម្មណ៍ និងសេដ្ឋកិច្ចសង្គម។ ជាញឹកញយស្ត្រីត្រូវបានសង្គម និងគ្រួសារបំភ្លេចចោល ហើយយកការចូលរួមនៅក្នុងសង្គមនិងសេដ្ឋកិច្ចរបស់ពួកគាត់ធ្វើជារឿងធម្មតា និងគិតថា កិច្ចការទាំងនេះជាភារកិច្ចរបស់គាត់ក្នុងនាមគាត់ជាកូនស្រី ជាបងប្អូនស្រី ជាភរិយា ជាម្តាយ ដែលត្រូវតែគិត ត្រូវតែធ្វើ សម្រាប់សង្គម និងគ្រួសារ»។ លោកស្រីបានបន្តជាសំណួរថា៖« តើរាងកាយរបស់យើងនឹងទៅជាយ៉ាងណា ប្រសិនបើឆ្អឹងខ្នងរបស់យើងទ្រុឌទ្រោម មានសុខភាពខ្សោយ ឬបាក់? ដូចគ្នាដែរ តើសង្គមយើង គ្រួសារយើងនឹងមានសភាពបែបណានៅពេលដែលស្ត្រី កុមារី ត្រូវបានគេរំលោភបំពាន និងមិនទទួលបាននូវសេវាជាមូលដ្ឋានចាំបាច់ក្នុងការរស់នៅប្រកបដោយសុខមាលភាព និងភាពថ្លៃថ្នូរ?»។

អគ្គលេខាធិការរងក្រុមប្រឹក្សាជាតិដើម្បីស្ត្រីលោកស្រី ចាន់ សុជាវី បានឲ្យដឹងថា ដើម្បីឲ្យស្ត្រីមានជំហររឹងមាំនិងមានឱកាសចូលរួមក្នុងសង្គមលុះត្រាតែមានការលុបបំបាត់ការរើសអើងចំពោះស្ត្រីគ្រប់ទម្រង់។ លោកស្រីបានបន្តថា៖« គ្មា ននរណាម្នាក់ដែលចង់ស្ថិតក្នុងភាពក្រីក្រលំបាក ឬការងារដែលមិនសមរម្យនោះទេ ប៉ុន្តែស្ថានភាពតម្រូវឲ្យស្ត្រីធ្វើបែបនេះ។ ទោះជាយ៉ាងណាក៏យើងជាស្ត្រីគឺត្រូវតែរឹងមាំ និងមានភាពវៃឆ្លាត ព្រោះគ្មានបញ្ហាណាមួយដែលគ្មានដែលគ្មានដំណោះស្រាយទេ»។

វេទិកាសិល្បៈស្ត្រីបានប្រើប្រាស់ការសម្តែងសិល្បៈចម្រុះ ការច្នៃជាពិព័រណ៍ រៀបរាប់និងឆ្លុះបញ្ចាំងពីវីរភាព ការតស៊ូ សាមគ្គីភាព និងការចូលរួមចំណែកយ៉ាងសកម្មក្នុងគោលបំណង ទីមួយ ដើម្បីពង្រឹងចលនាសាមគ្គីភាពរបស់ស្ត្រីនៅកម្ពុជា ទីពីរ ដើម្បីបង្ហាញពីប្រភព និងវីរភាពរបស់ស្ត្រី រួមទាំងបញ្ហាដែលស្ត្រីជួបប្រទះនៅក្នុងវិស័យសេដ្ឋកិច្ចទាំងនៅក្នុងផ្ទះ និងសង្គមខាងក្រៅ ទីបីដើម្បីធ្វើការលើកឡើងនូវតម្រូវការរបស់ស្ត្រីពីគ្រួសារ សហគមន៍ និងសង្គមជាជាពិសេសតម្រូវការក្នុងការទទួលបានសេវាសង្គមមូលដ្ឋានប្រកបដោយគុណភាព និងសមធម៌៕

## តើកិច្ចសន្យាប្រភេទ...

គោរពតាមការសម្រេចចិត្តរបស់ក្រសួងការងារ។ ក្រោយការព្យាយាមទាក់ទងទៅគាត់ម្តងជាពីរដង គាត់ក៏បានសន្យាថាគាត់នឹងជួយជំរុញឲ្យខាងរោងចក្រចូលរួមដោះស្រាយ។

ក្នុងអំឡុងពេលរង់ចាំដំណឹងពីខាងក្រសួងការងារ អ្នកទាំងពីរបានទទួលទូរសព្ទពីមនុស្សម្នាក់ដែលគេអះអាងថាគេជាកម្មករនៅបែកចាន និងត្រូវបានក្រុមហ៊ុនបញ្ជូនឲ្យទំនាក់ទំនងជាមួយកម្មការិនីសុខណាត ដោយបញ្ជាក់ថាក្រុមហ៊ុន នឹងបន្ថែមលុយឲ្យអ្នកទាំងពីរម្នាក់១០០ដុល្លារ ដើម្បីបញ្ចប់រឿង។ ជាមួយគ្នានេះដែររដ្ឋបាលរោងចក្របានហៅទូរស័ព្ទមកអ្នកទាំងពីរ ដើម្បីចរចាដោយភាគីខាងរោងចក្របន្ថែមលុយឲ្យម្នាក់៣០០ដុល្លារទៀត។ ទោះបីជាយ៉ាងណាអ្នកទាំងពីរមិនព្រមទទួលយកនោះទេ ដោយពួកគេទាមទារឲ្យខាងរោងចក្រធ្វើទៅតាមផ្លូវច្បាប់។

លុះរហូតមកដល់ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ក្រសួងបានហៅភាគីទាំងសងខាងមកផ្សះផ្សា ដោយក្នុងនោះមានភាគីខាងក្រុមហ៊ុនម្នាក់តំណាងក្រសួងម្នាក់និងកម្មករពីរនាក់។ អ្នកទាំងពីរនៅតែលើកយកមាត្រា៦៧ នៃច្បាប់ស្តីពីការងារមកជជែក និងអះអាងថាកិច្ចសន្យារបស់ខ្លួនត្រូវក្លាយជាកិច្ចសន្យាគ្មានថេរវេលាកំណត់ ដូច្នេះការបញ្ចប់កិច្ចសន្យាត្រូវធ្វើតាមច្បាប់ស្តីពីការងារ។

ក្រោយការផ្សះផ្សាគ្នានៅក្រសួងការងារនៅថ្ងៃទី០៥ ខែធ្នូដដែលរដ្ឋបាលរោងចក្របានទូរសព្ទទៅអ្នកទាំងពីរដើម្បីទូទាត់ប្រាក់សំណងតាមផ្លូវច្បាប់។ ជាលទ្ធផលពួកគេម្នាក់ៗទទួលបាន៧៥០ដុល្លារអាមេរិក៕

បោះពុម្ពផ្សាយដោយ
WORKER'S INFORMATION CENTER
អាសយដ្ឋាន: ផ្ទះលេខ៣-៤ ផ្លូវលេខ៣៣៩ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទូរស័ព្ទ: ០១៧ ២២៩ ៥០០
អ៊ីមែល: communication.wic@gmail.com
គេហទំព័រ: www.wic.unitedsisterhood.org



ព្រឹត្តិបត្រ
ចេញផ្សាយខែមករា ឆ្នាំ២០១៧
# ទំព័រកម្មករ
ឆ្អឹងខ្នងសេដ្ឋកិច្ចជាតិ វីរភាពគួរចងចាំ
លេខទី៤



## វេទិកាសិល្បៈស្ត្រី «វីរភាពស្ត្រីក្នុង វិស័យសេដ្ឋកិច្ច»

សម្ព័ន្ធបងប្អូនស្រីរួមមានក្រុមតន្ត្រីយុវវ័យនាំសារ បណ្តាញការងារស្ត្រីរួបរួមគ្នា សមាគមមណ្ឌលព័ត៌មានកម្មករ និងសកម្មភាពសង្គមដើម្បីការផ្លាស់ប្តូររួមជាមួយនឹងកម្មការិនីរោងចក្រកាត់ដេរនិងស្ត្រីប្រកបរបរផ្លូវភេទ និងសេវាកម្សាន្ត កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៦ បានរៀបចំវេទិកាសិល្បៈស្ត្រីក្រោមប្រធានបទ «វីរភាពស្ត្រីក្នុងវិស័យសេដ្ឋកិច្ច» នៅសាលមហោស្រពចេនឡា ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងកិច្ចការនារី សិស្ស និស្សិត សិល្បករ សិល្បការិនី កម្មការិនី កម្មករ រោងចក្រកាត់ដេរស្ត្រីប្រកបរបរផ្លូវភេទ អង្គការមិនមែនរដ្ឋាភិបាល និងសាធារជនទូទៅប្រមាណជាង ៥០០នាក់។ ស្ត្រីបានចូលរួមចំណែកយ៉ាងសកម្ម ដោយលះបង់ទាំងកម្លាំងកាយចិត្តក្នុងវិស័យសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រព័ន្ធរបស់កម្ពុជា ដើម្បីបង្កើនជីវភាពរស់នៅរបស់គ្រួសារក៏ដូចជាធ្វើឲ្យវឌ្ឍនភាពសង្គមមានភាពប្រសើរឡើង។ ការរួមចំណែករបស់ស្ត្រីគឺជាការលះបង់ដែលមិនអាចកាត់ថ្លៃបាន ហើយជាវីរភាពមួយដែលមិនគួរមើលរំលង និងគួរតែទទួលបាននូវការសាទរ ការយកចិត្តទុកដាក់ ព្រមទាំងការគាំពារពីគ្រប់មជ្ឈដ្ឋាន។

កម្មការិនី អ៊ុន សុភា បានលះបង់កម្លាំងកាយចិត្តក្នុងការធ្វើការងារជាកម្មការិនីរោងចក្រអស់រយៈពេល១៩ឆ្នាំ គឺដើម្បីលើកស្ទួយជីវភាពគ្រួសារ និងសង្គមជាតិ។ សុភាបានលើកឡើងថា៖ « ពេលខ្ញុំមកធ្វើការរោងចក្រខ្ញុំបានយកកម្រៃដែលខ្ញុំទទួលបានទៅឲ្យប្អូនបន្តការសិក្សានៅសាកលវិទ្យាល័យពីរនាក់ បន្ទាប់មកចំណាយទៅលើគ្រួសារ និងបន្តិចបន្តួចទុកសម្រាប់ចំណាយលើការរស់នៅប្រចាំថ្ងៃ។ កត្តាជំរុញឲ្យខ្ញុំនៅតែបន្តទៅទៀត ដោយសារតែខ្ញុំចង់ឲ្យប្អូនខ្ញុំរៀនចប់មហាវិទ្យាល័យ ហើយមានការងារល្អធ្វើ»។

ស្រដៀងគ្នានេះដែរ អ៊ុក រស្មី ស្ត្រីប្រកបរបរសេវាកម្សាន្តរយៈពេល៤ឆ្នាំ បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីគាំទ្រជីវភាពគ្រួសារ។ ស្ត្រីមេម៉ាយរូបនេះបានឲ្យដឹងថា៖ «ខ្ញុំធ្វើការរកស៊ីរាល់ថ្ងៃដើម្បីម្តាយរបស់ខ្ញុំដែលគាត់មានជំងឺ និងកូនរបស់ខ្ញុំ។ ខ្ញុំមានមោទនភាពចំពោះខ្លួនឯងដែលខ្ញុំមេម៉ាយមែន តែខ្ញុំតស៊ូ ខ្ញុំនៅថៃទាំរកស៊ីចិញ្ចឹមគាត់និងកូនរបស់ខ្ញុំ»។

ទោះបីស្ត្រីជាឆ្អឹងខ្នងសេដ្ឋកិច្ចសង្គម និងគ្រួសារ ប៉ុន្តែបើតាមការលើកឡើងរបស់ប្រធានសមាគមមណ្ឌលព័ត៌មានកម្មករ និងជាតំណាងសម្ព័ន្ធបងប្អូនស្រី លោកស្រី ម៉ាក ច័ន្ទស៊ីថា បានឲ្យដឹងថាគ្រួសារ និងសង្គមហាក់មិនសូវជាចាប់អារម្មណ៍ក្នុងការថៃទាំគាំទ្រផ្តល់ភាពកក់

តទៅទំព័រ ៤

## តើអ្វីនៅពីក្រោយប្រាក់ឈ្នួលកើនឡើង?

ប្រាក់ឈ្នួលគោលកម្មករតែងកើនឡើងរៀងរាល់ឆ្នាំប្រមាណជា១២ដុល្លារទៅ១៣ដុល្លារ។ នៅក្នុងអំឡុងខែកក្កដាតែងតែមានកិច្ចប្រជុំរវាងក្រសួងការងារ សហជីពដែលជាតំណាងកម្មករ និងតំណាងខាងរោងចក្រ ដើម្បីពិភាក្សាគ្នាពីបញ្ហាប្រាក់ឈ្នួលរបស់កម្មករ។ ជាលទ្ធផលនៅខែមករា ប្រាក់ឈ្នួលគោលនឹងកើនឡើងយ៉ាងហោចណាស់១២ដុល្លារក្នុងមួយខែ។ តើអ្វីនៅពីក្រោយប្រាក់ឈ្នួលកើនឡើងនេះ?

### តើស្ថានភាពការងារមានសភាពបែបណា?

ស្របពេលដែលប្រាក់ឈ្នួលបានកើនឡើង លក្ខខណ្ឌការងារនៅក្នុងរោងចក្រកាន់តែមានស្ថានភាពតឹងតែងជាងមុន។ កម្មការិនី-កម្មករ ត្រូវប្រឈមនឹងកិច្ចសន្យាមានថេរវេលាកំណត់ (កិច្ចសន្យាខ្លី) ដែលធ្វើឲ្យពួកគេងាយប្រឈមការបញ្ឈប់ពីការងារ នៅពេលពួកគេតវ៉ាពីបញ្ហាអយុត្តិធម៌ណាមួយ។ អ្វីដែលគួរឲ្យកត់សម្គាល់ជាងនេះទៀតនោះ គឺការកំណត់ចំនួននៅតាមរោងចក្រមួយចំនួនមានការកើនឡើងស្ទើរតែទ្វេដងបើធៀបនឹងចំនួនកំណត់ពីឆ្នាំកន្លងទៅ។ នៅពេលកម្មករធ្វើការមិនគ្រប់ការកំណត់ ពួកគេនឹងត្រូវប្រធានក្រុម ប្រធានផ្នែក និងចិនស្តីបន្ទោស។ លើសពីនេះទៀតក៏មានការកាត់បន្ថយកម្មករក្នុង សង្វាក់ផលិតកម្មយ៉ាងហោចណាស់៣ ទៅ១០នាក់។ មិនត្រឹមតែប៉ុណ្ណោះការបង្ខំឲ្យធ្វើការថែមម៉ោងក្នុងរូបភាពផ្តល់ប្រាក់រង្វាន់ ក៏កើតមានច្រើនផងដែរ។ តើប្រាក់ឈ្នួលគោលបានកើនឡើងនេះសមាមាត្រនឹងកម្លាំងពលកម្មរបស់កម្មករដែរឬទេ?

**តើប្រាក់ឈ្នួលគោលកើនឡើងជាង ១០ដុល្លានេះចូលក្នុងហោប៉ៅកម្មករទាំងអស់មែនឬទេ?**

តទៅទំព័រ ២

អំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០១៦ ក្រុមកម្មករផ្នែកអ៊ុត និងដេរនៅរោងចក្រអេវើហ្គ្រីនបាននាំគ្នាទាមទារឲ្យលក្ខខណ្ឌការងារល្អប្រសើរជាងមុន។ បន្ទាប់ពីការទាមទារមិនមានការឆ្លើយតប ក្រុមកម្មករទាំងនោះបានស្នើឲ្យកម្មករពីរនាក់ដែលម្នាក់ជាអ្នកចងក្រង និងម្នាក់ទៀតជាកម្មករសកម្មនៅសមាគមមណ្ឌលព័ត៌មានកម្មករ ជួយសម្របសម្រួលកិច្ចពិភាក្សា និងវិភាគជាមួយពួកគេ។ ក្រោយមកក៏លើកអ្នកទាំងពីរធ្វើជាតំណាងរបស់ខ្លួនក្នុងការចរចាជាមួយរោងចក្រ។ បន្ទាប់ពីមានការចរចាជាច្រើនលើកច្រើនសារ ប៉ុន្តែនៅតែគ្មានដំណោះស្រាយ។ ចុងក្រោយកម្មករ និងតំណាងរបស់ពួកគេបានជជែកគ្នារកយុទ្ធសាស្ត្រ ដើម្បីដាក់សម្ពាធឲ្យរោងចក្រមានការឆ្លើយតប។ ពួកគេបានព្រមព្រៀងគ្នាមិនទៅធ្វើការរយៈពេលមួយខែកន្លះ រហូតទាល់តែមានការឆ្លើយតបពីរោងចក្រ។

# កម្មការិនី និងភាពជាអ្នកដឹកនាំ

កម្មការិនីទាំងពីរនាក់ត្រូវបានកម្មករស្នើសុំឲ្យជួយសម្របសម្រួលការពិភាក្សា និងការវិភាគពីស្ថានភាពនៅក្នុងរោងចក្រ ហើយពួកគេក៏ត្រូវបានជ្រើសតាំងធ្វើជាតំណាងសំរាប់កិច្ចចរចាជាមួយរោងចក្រ។ ជាមួយភាពជាអ្នកដឹកនាំរបស់ស្ត្រីទាំងពីររូប កម្មករបានទទួលលទ្ធផលជាទីពេញចិត្ត ហើយពួកគេក៏មានការកោតសរសើរចំពោះអ្នកទាំងពីរ។ ចំពោះលទ្ធផលដែលទទួលបាន រួមមានទម្លាក់ការកំណត់ចំនួនខោរបិយពីចំនួន៦០០ មកត្រឹម៤០០ក្នុងមួយថ្ងៃ បន្ថែមកង្ហាចំនួន ១០កង្ហា នៅផ្នែកអ៊ុត និងបន្ថែមម៉ាស៊ីនសាប់ចំនួនពីរ ដើម្បីភាពងាយស្រួលដល់កម្មករក្នុងការផលិត។ លទ្ធផលនេះបានធ្វើឲ្យអ្នកចងក្រង WIC បានជាប់ឆ្នោតធ្វើជាលេខាធិការនៅក្នុងសហជីពអំណាចកម្មករ ខណៈពេលដែលកម្មករសកម្មរបស់ WIC ត្រូវបានជ្រើសតាំងធ្វើជាលេខាធិការនៅសហជីពសេរីកម្មករ (FTUWKC) កាលពីខែវិច្ឆិកា ២០១៦។

លទ្ធផលដែលទទួលបាននេះ ក៏ដូចជាមានការទទួលស្គាល់ពួកគេពីសំណាក់កម្មករដទៃទៀតនៅក្នុងរោងចក្របានបង្ហាញពីសមត្ថភាព និងភាពជាអ្នកដឹកការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ជំនាញពីសមាគមមណ្ឌលព័ត៌មានកម្មករ។ ជាមួយគ្នានេះដែរ ភាពជាអ្នកដឹកនាំនិងភាពជាតំណាងរបស់ពួកគេបានជំរុញឲ្យពួកគេចេះចរចា និងរៀបចំយុទ្ធសាស្ត្រសម្រាប់ជួយឲ្យលក្ខខណ្ឌការងារនៅក្នុងរោងចក្រមានភាពប្រសើរឡើង៕

# តើអ្វីនៅពីក្រោយ...

នៅពេលប្រាក់ឈ្នួលកម្មករកើនឡើងជាង១០ដុល្លារ ម្ចាស់ផ្ទះជួលភាគច្រើនដំឡើងថ្លៃបន្ទប់ជួលរបស់ខ្លួនពី៥ដុល្លារទៅ១០ដុល្លារ ខណៈដែលស្ថានភាពបន្ទប់ជួលគ្មានការជួសជុលឲ្យប្រសើរជាងមុន។ បន្ទប់ជួលកម្មករមានទំហំ ២ម៉ែត្រx២,៥ម៉ែត្រ ២ម៉ែត្រx៣ម៉ែត្រ ខ្វះអនាម័យ និងគ្មានសុវត្ថិភាព។ បន្ទប់ទាំងនោះភាគច្រើនលិចទឹកនៅពេលភ្លៀងធ្លាក់ខ្លាំង។ បន្ទប់មួយចំនួនទៀតគ្មានបន្ទប់ទឹកនៅខាងក្នុង ដូច្នេះអ្នកជួលទាំងអស់ត្រូវប្រើប្រាស់បន្ទប់ទឹករួមគ្នានៅខាងក្រៅ។ លើសពីនេះទៀតប្លុកផ្ទះជួលមួយចំនួនមានបន្ទប់ទឹកត្រឹម៤បន្ទប់ សម្រាប់ឲ្យអ្នកជួលប្រើប្រាស់លើសពី៥០នាក់។ ដូច្នេះនៅពេលម្ចាស់ផ្ទះជួលទាមទារឡើងថ្លៃ ខណៈពេលស្ថានភាពបន្ទប់គ្មានការកែលម្អ តើវាសមស្របដែលអាចទទួលយកបានដែរឬទេ? កម្មករភាគច្រើនមិនពេញចិត្តជាមួយការឡើងថ្លៃនេះ ប៉ុន្តែគ្មានជម្រើសនិងដំណោះស្រាយ។ ម៉្យាងវិញទៀតតម្លៃទំនិញផ្សេងៗនៅលើទីផ្សារក៏មានការឡើងថ្លៃផងដែរ។

## តើកម្មករបានធ្វើអ្វីខ្លះ?

ក្នុងឆ្នាំ២០១៤ សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ដែលហៅកាត់ថា ស៊ីខៅឌូ បានធ្វើយុទ្ធនាការមួយប្រឆាំងនឹងការឡើងថ្លៃបន្ទប់ជួល។

នៅដើមឆ្នាំ២០១៦ តម្លៃបន្ទប់ជួលនៅតែឡើងថ្លៃ។ អ្នកសម្របសម្របនៅមណ្ឌលសំចតរបស់សមាគមមណ្ឌលព័ត៌មានកម្មករបានដឹងពីបញ្ហានេះ ពួកគេក៏ចាប់ផ្តើមជួបជជែកពីបញ្ហាការឡើងថ្លៃនេះនៅតាមប្លុកដែលឡើងថ្លៃទាំងនោះ។ នៅក្នុងការជជែកនោះក៏មានការវិភាគពីស្ថានភាពការងារ និងការរស់នៅ។ មុនពេលដែលត្រូវទទួលបានប្រាក់ឈ្នួល ១០ដុល្លារពីការលក់កម្លាំងពលកម្មរបស់ខ្លួន តើពួកគេត្រូវធ្វើអ្វីខ្លះ? តើពួកគេប្រឈមមុខនឹងបញ្ហាអ្វីខ្លះ? ចុះបន្ទប់ជួលវិញ ហេតុអ្វីម្ចាស់ផ្ទះជួលត្រូវឡើងថ្លៃបន្ទប់? បន្ទាប់ពីមានការយល់ដឹងស៊ីជម្រៅ កម្មករបានចុះទៅចងក្រងអ្នកជួលផ្សេងទៀតក្នុងប្លុកជាមួយគ្នា ដើម្បីឲ្យពួកគេយល់ពីបញ្ហានេះដែរ។ នៅពេលទទួលបានសំឡេងច្រើនដែលមិនពេញចិត្តក្នុងការឡើងថ្លៃបន្ទប់នេះពួកគេបានជ្រើសរើសតំណាងរបស់ខ្លួនក្នុងការចរចាជាមួយម្ចាស់ផ្ទះជួល។ ប៉ុន្តែមុននឹងឈានដល់ការចរចាជាមួយម្ចាស់ផ្ទះជួលពួកគេមានការពិភាក្សាគ្នា និងរៀបចំយុទ្ធសាស្ត្រផងដែរ។ ជាលទ្ធផលម្ចាស់ផ្ទះមួយចំនួនបានយល់ព្រមមិនតម្លើងថ្លៃបន្ទប់ជួលតាមការស្នើសុំរបស់កម្មករ។ ដោយឡែកម្ចាស់ផ្ទះជួលខ្លះ ដែលមិនយល់ព្រមតាមការស្នើសុំរបស់អ្នកជួលពួកគេក៏សម្រេចចិត្តរើបន្ទប់ចេញពីផ្ទះជួលនោះ។

ក្រោយពីយុទ្ធនាការទទួលបានជោគជ័យ រួមជាមួយនឹងច្បាប់ភតិសន្យាពិសេសដែលបានអនុម័តដោយរដ្ឋសភាជាតិ គេសង្កេតឃើញថាស្ថានភាពឡើងថ្លៃបន្ទប់ជួលហាក់មានសភាពស្ងប់ស្ងាត់បន្តិចក្រោយពីប្រាក់ឈ្នួលកម្មករបានកើនឡើងនៅឆ្នាំ២០១៧នេះ៕





# តើកិច្ចសន្យាប្រភេទណា ជាកិច្ចសន្យាមិនមានថេរវេលាកំណត់?

វិស័យឧស្សាហកម្មវាយនភណ្ឌកាត់ដេរ គឺជាផ្នែកមួយដ៏សំខាន់ក្នុងការរកចំណូលចូលជាតិនៅឆមាសទីមួយក្នុងឆ្នាំ ២០១៦ ចំណូលពីការនាំចេញសម្លៀកបំពាក់នៅបន្តកើនឡើងដែលធ្វើឲ្យវិស័យនេះនៅតែជាឆ្អឹងខ្នងសេដ្ឋកិច្ចជាតិអស់រយៈពេលជាង២ទស្សវត្សរ៍មកហើយ។ ប៉ុន្តែក្រឡេកទៅមើលស្ថានភាពនៅក្នុងរោងចក្រវិញកម្មករភាគច្រើនត្រូវបានគេបញ្ចប់កិច្ចសន្យា ក្រោមហេតុផលរោងចក្រគ្មានការបញ្ជាទិញ ឬក្ស័យធន។

ជាក់ស្តែងរោងចក្រអ៊ីស្ទីច ជារោងចក្រផលិតសម្លៀកបំពាក់ ដែលកម្មករនិយាយតៗគ្នាថាបានដំណើរការតាំងពីឆ្នាំ២០០៦មកម្ល៉េះ ហើយពីមួយឆ្នាំទៅមួយឆ្នាំរោងចក្របានរីកចម្រើនកាន់តែខ្លាំងឡើងៗ រហូតមានការបង្កើតសាខាថ្មីៗនៅតាមបណ្តាខេត្ត និងក្បែររាជធានីភ្នំពេញ។ ប៉ុន្តែនៅដើមខែសីហា ឆ្នាំ២០១៦ រោងចក្រនេះបានចាប់ផ្តើមបញ្ចប់កិច្ចសន្យាជាមួយកម្មករប្រមាណ ៣០នាក់ ទៅ២០០នាក់ក្នុងមួយថ្ងៃ ដោយរោងចក្រប្រកាសប្រាប់កម្មករថា រោងចក្រក្ស័យធន និងគ្មានការងារឲ្យកម្មករធ្វើ។

អៀង សុខណាត និង តេលា ជាកម្មកររោងចក្រអ៊ីស្ទីចអស់រយៈពេលជាងបីឆ្នាំ។ អ្នកទាំងពីរត្រូវបានរោងចក្របញ្ចប់កិច្ចសន្យា ហើយរោងចក្រសន្យាផ្តល់សំណង៣៣១ដុល្លារអាមេរិក ដែលក្នុងនោះរួមមានប្រាក់៥ភាគរយ ប្រាក់បំណាច់ឆ្នាំ ប្រាក់ខែចុងក្រោយ និងប្រាក់អត្ថប្រយោជន៍ផ្សេងទៀត ប៉ុន្តែមិនមានប្រាក់សងជំងឺចិត្តនោះទេ ព្រោះរដ្ឋបាលរោងចក្រអះអាងរោងចក្រក្ស័យធនទើបមិនមានលុយជំងឺចិត្ត។ ដោយភាពមិនច្បាស់លាស់ តេលា បានសួរទៅរដ្ឋបាលថាប្រសិនបើរោងចក្រក្ស័យធន តើមានលិខិតបញ្ជាក់ពីក្រសួងការងារឬទេ?ប៉ុន្តែរដ្ឋបាលមិនបានឆ្លើយតបនោះទេ ហើយសហជីពបានឲ្យនាងទៅសួរថៅកែដោយខ្លួនឯង។ ដោយគិតថាប្រាក់សំណង ៣៣១ដុល្លារអាមេរិក ជាប្រាក់សំណងមិនត្រឹមត្រូវតាមច្បាប់ អ្នកទាំងពីរនិងកម្មការិនីម្នាក់ទៀតមិនទទួលយកនោះទេ ខណៈដែលកម្មករ ៤០នាក់ផ្សេងទៀតបានយល់ព្រមចុះហត្ថលេខាទទួលយកប្រាក់បញ្ចប់កិច្ចសន្យា។

ទាំងតំណាងកម្មករ សហជីព និងរដ្ឋបាលរោងចក្របានព្យាយាមជួបជជែក និងបញ្ចុះបញ្ចូលឲ្យអ្នកទាំងបីទទួលយកប្រាក់សំណងបញ្ចប់កិច្ចសន្យានេះ។

តេលាបានឲ្យដឹងថា៖ «សហជីពប្រាប់ខ្ញុំថា ហ្អែងចង់បានអីទៀតលុយជំងឺចិត្តអីគ្មានទេព្រោះហែងកិច្ចសន្យាខ្លីមានតែលុយជូនដំណឹងនិងលុយប៉ុន្មាន



*កម្មការិនី អៀង សុខណាត*

ចំណុចដូចប្រាប់ពីមុនហ្នឹងទេ ហើយបើចង់ទៅប្តឹងនៅឯណាក៏មិនឈ្នះគេដែរ»។ ក្រោយការជជែករវាងរដ្ឋបាល និងកម្មការិនីទាំងបីមួយសាជាពីរសាកម្មការិនីម្នាក់បានសម្រេចចិត្តទទួលយកលុយនោះ ព្រោះគាត់អះអាងថា គាត់មិនអាចចាំបានទេ ហើយម៉្យាងទៀតមិត្តភក្តិនិងកូនៗរបស់គាត់ បានឲ្យគាត់ទទួលយកលុយដើម្បីបញ្ចប់រឿង។

សុខណាត និងតេលាជាកម្មករសកម្មនៅមណ្ឌលព័ត៌មានកម្មកររយៈពេលជាងមួយឆ្នាំ។ ដោយភាពមិនអស់ចិត្ត អ្នកទាំងពីរបានមកជជែកពិភាក្សានិងវិភាគពីស្ថានភាពជាមួយអ្នកសម្របសម្រួលអ្នកចងក្រង និងកម្មករសកម្មនៅមណ្ឌលសំចតជម្ពូវ័ន។ អ្នកទាំងពីរបានព្យាយាម



*កម្មការិនី តេលា*

គៀងគរកម្មករដទៃទៀតដែលរោងចក្របញ្ចប់កិច្ចសន្យាដូចគ្នា ដើម្បីដាក់ពាក្យបណ្តឹងទៅក្រសួងការងារ ជាលទ្ធផលអ្នកដែលយល់ព្រមដាក់ពាក្យប្តឹងមាន ៤នាក់ នៅថ្ងៃទី០៦ កញ្ញា ឆ្នាំ ២០១៦។ នៅពេលចូលបំភ្លឺនៅក្រសួងការងារនៅថ្ងៃទី០៦ តុលា ឆ្នាំ ២០១៦ សុខណាតបានឲ្យដឹងថា៖ «ក្រសួងការងារនិយាយថា តើយើងទាមទារឲ្យក្រុមហ៊ុនទូទាត់សំណងតាមច្បាប់បែបណា? បើយើងមានកិច្ចសន្យាខ្លីត្រឹម ៦ខែហ្នឹង ហើយយើងក៏ស៊ីញ៉េយកលុយ៥% រាល់ពេលបញ្ចប់កិច្ចសន្យាទៀត»។ នាងឆ្លើយតបទៅវិញថា «ខ្ញុំនៅតែយល់ថាវាមិនត្រឹមត្រូវទេ ព្រោះខ្ញុំធ្វើការលើសពី៣ឆ្នាំ តាមច្បាប់ស្តីពីការងារមាត្រាទី៦៧ បើធ្វើកិច្ចសន្យាលើសពីពីរឆ្នាំ ត្រូវក្លាយជាកិច្ចសន្យាមិនកំណត់ ហើយចឹងលុយខ្ញុំត្រូវច្រើនជាងហ្នឹង ហើយការជូនដំណឹងរបស់ក្រុមហ៊ុនក្នុងការផ្តាច់កិច្ចសន្យា ក៏មិនត្រឹមត្រូវដែរ»។ ក្រោយការបំភ្លឺកម្មការិនី ឌុក សម្បត្តិ ត្រូវដកពាក្យបណ្តឹងវិញ ព្រោះនាងមិនទាន់ត្រូវក្រុមហ៊ុនបញ្ចប់កិច្ចសន្យា ចំណែកកម្មការិនីម្នាក់ទៀតមិនបានទៅបំភ្លឺនៅក្រសួងទេ ព្រោះក្រុមរបស់គាត់ទាក់ទងគាត់មិនបាន ដូច្នេះក្រសួងក៏ចាត់ទុកពាក្យបណ្តឹងរបស់គាត់ជាមោឃៈ។

ទន្ទឹមនឹងការដាក់ពាក្យបណ្តឹងទៅក្រសួងការងារ សុខណាត និងតេលាក៏បានសរសេរលិខិតទៅស្លាកសញ្ញាH&M ដើម្បីសុំអន្តរាគមន៍ផងដែរ ប៉ុន្តែតំណាងម្ចាស់ស្លាកបានប្រាប់អ្នកទាំងពីរថា គាត់

តទៅទំព័រ ៤